រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ២០១៦

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ របៀបបំពេញលិខិតប្រកាសពន្ធលើប្រាក់ចំណេញ និងវិធានប្រើប្រាស់វិក្កយបត្រសម្រាប់អ្នកជាប់ពន្ធ តាមរបបស្វ័យប្រកាស




*© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ*

នាវេលាម៉ោង ០៨:៣០ នាទីព្រឹក ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៦ នៅសាលសិក្ខាសាលា ជាន់ទី១០ នៃសាលាជាតិពន្ធដារ (អគ្គនាយកដ្ឋានពន្ធដារ) មានការរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី «ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ របៀបបំពេញលិខិតប្រកាសពន្ធលើប្រាក់ចំណេញ និងវិធានប្រើប្រាស់វិក្កយបត្រសម្រាប់អ្នកជាប់ពន្ធ តាមរបបស្វ័យប្រកាស» ដែលបានរៀបចំឡើងដោយអគ្គនាយកដ្ឋានពន្ធដារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ និងមានការចូលរួមពីសំណាក់ លោកប្រធាន- អនុប្រធាននាយកដ្ឋាន លោកប្រធាន- អនុប្រធានការិយាល័យ និងមន្ត្រីមួយចំនួននៃអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងមានការចូលរួមពីសំណាក់ លោកឧកញ៉ា លោកជំទាវ លោក-លោកស្រី នាងកញ្ញា ជានាយក ឬតំណាងរោងចក្រ-សហគ្រាស ចំនួន ៣០០ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ។

ជាកិច្ចចាប់ផ្តើមឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ បានថ្លែងអំណរគុណ ចំពោះលោកជំទាវ លោកឧកញ៉ា លោក-លោកស្រី នាងកញ្ញា តំណាងក្រុមហ៊ុននានា ដែលមានវត្តមានចូលរួមនៅក្នុងអង្គសិក្ខាសាលាដ៏មានសារៈសំខាន់នេះ ដែលសបញ្ជាក់ឱ្យឃើញពីការយកចិត្តទុកដាក់ខ្ពស់ ក្នុងការគោរពប្រតិបត្តិច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ។ សិក្ខាសាលា



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

នេះ ត្រូវបានរៀបចំធ្វើឡើងក្នុងគោលបំណងផ្សព្វផ្សាយ ឱ្យបានកាន់តែទូលំទូលាយថែមទៀតនិងឱ្យបានជ្រួតជ្រាបដល់មជ្ឍដ្ឋានអ្នកជាប់ពន្ធជាពិសេសគឺដើម្បីស្វែងយល់ឱ្យបានកាន់តែស៊ីជម្រៅថែមទៀត សំដៅធ្វើយ៉ាងណាឱ្យអ្នកជាប់ពន្ធគោរពឱ្យបានខ្ជាប់ខ្ជួន នូវការអនុវត្តច្បាប់ស្តីពីសារពើពន្ធ និងចៀសវាងបាននូវកំហុសឆ្គង ដោយប្រការណាមួយ ដែល អាចនាំទៅដល់ការទទួលនូវការ ផាកពិន័យ និងទោសទណ្ឌផ្សេងៗ ពីសំណាក់រដ្ឋបាលសារពើពន្ធ។

សិក្ខាសាលាដ៏មានសារៈសំខាន់នេះ នឹងរួមចំណែកខ្ពស់ ក្នុងការពង្រឹងការអនុវត្តកាតព្វកិច្ចសារពើពន្ធ ហើយតាមរយៈសិក្ខាសាលានេះ សិក្ខាកាមចូលរួមទាំងអស់ នឹងទទួលបាននូវចំណេះដឹងថ្មីៗបន្ថែមទៀត ស្តីពីពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ នីតិវិធីនៃការបំពេញលិខិតប្រកាសបង់ពន្ធ លើប្រាក់ចំណេញប្រចាំឆ្នាំជាពិសេស គឺគំរូនៃការប្រើប្រាស់វិក្កយបត្រ សម្រាប់អ្នកជាប់ពន្ធ តាមរបបស្វ័យប្រកាស។

ជាទីបញ្ចប់ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ បានជូនពរលោកឧកញ៉ា លោកជំទាវ លោក-លោកស្រី ព្រមទាំងសិក្ខាកាមទាំងអស់ សូមសមប្រកបនឹងពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ